ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ២៩១៧ ព.ណ..ភ៣...

ថ្ងៃ ចន្ទ ១១ កើត ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០២០

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅ ឲ្យបានជ្រាបថា ក្រសួង នឹងបន្តរៀបចំ **"ពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូលអន្តរជាតិលើកទី១៥"** ចាប់ពីថ្ងៃទី១៥-១៨ ខែធ្នូ ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលតាំងពិព័រណ៍ និងសន្និបាតកោះពេជ្រ រាជធានីភ្នំពេញ។

ការរៀបចំព្រឹត្តិការណ៍នេះ ក្នុងគោលបំណងជំរុញសកម្មភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជាតភ្ជាប់ទំនាក់ទំនងសេដ្ឋកិច្ចគ្រប់ប្រព័ន្ធរវាងរាជធានី-ខេត្តទូទាំងប្រទេស ដើម្បីរួមចំណែកដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចជាតិឡើងវិញបន្ទាប់ពីជួបវិបត្តិជំងឺឆ្លងកូវីដ-១៩។ ដោយស្ថានភាពនៃជំងឺឆ្លងកូវីដ-១៩ នៅក្នុងពិភពលោកមិនទាន់អាចគ្រប់គ្រងបានទាំងស្រុង និងភាពមិនច្បាស់លាស់អំពីស្ថានភាពនៃជំងឺនេះ ក្រសួងពាណិជ្ជកម្ម នឹងផ្ដល់អាទិភាពខ្ពស់ចំពោះក្រុមហ៊ុន សហគ្រាសក្នុងស្រុក និងអនុញ្ញាតឲ្យក្រុមហ៊ុនបរទេសដែលមានសាខា ឬ ភ្នាក់ងារលក់របស់ខ្លួននៅក្នុងប្រទេសកម្ពុជាស្រាប់ នាំយកផលិតផលទំនិញ សេវា និងគម្រោងវិនិយោគនានាមកដាក់តាំងបង្ហាញដើម្បីស្វែងរកដៃគូពាណិជ្ជកម្ម។ ក្នុងអំឡុងពេលពិធីនោះផងដែរ ក្រសួងនឹងសហការជាមួយគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយអនុវត្តតាមស្តង់ដារសុខាភិបាលជាតិ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ក្រសួងពាណិជ្ជកម្មសូមអញ្ជើញពាណិជ្ជករ ផលិតករ សមាគមអាជីវកម្ម និងក្រុមហ៊ុនពាណិជ្ជកម្ម ដែលមានបំណងចង់ចូលរួមក្នុងព្រឹត្តិការណ៍**ពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ-នាំចូលអន្តរជាតិលើកទី១៥ ឆ្នាំ២០២០** ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្ម និងវិនិយោគ សូមអញ្ជើញមកបំពេញបែបបទនៅនាយកដ្ឋានកិច្ចការពិព័រណ៍ នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ឲ្យបានមុនថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ ជាកំណត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនាយកដ្ឋានកិច្ចការពិព័រណ៍ ដែលមានទីតាំងស្ថិតនៅជាន់ទីពីរ នៃអាគារទីស្តីការក្រសួងពាណិជ្ជកម្ម អាសយដ្ឋាន៖ ដីឡូត៍លេខ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ទូរស័ព្ទទាក់ទង៖ ០៧៨ ៧៥៥ ៥៥១ ឬ ០៧៧ ៣៣៩ ៤៣៩ ឬ ០៧៧ ៣៣២ ២៣៣
ឬ ០១៧ ៤៩៥ ០៩១

អាសយដ្ឋានអ៊ីមែល៖ ritatong19@gmail.com ឬ neary86@gmail.com ឬ
vuthakep@yahoo.com ឬ kdi_mpp@yahoo.com

សម្គាល់៖ ក្រសួងពាណិជ្ជកម្ម សូមរក្សាសិទ្ធិកែប្រែកម្មវិធីរៀបចំព្រឹត្តិការណ៍ខាងលើប្រសិនបើមានការចាំបាច់។

**សូមអរគុណ!**

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°2917.MOC.D./.EA

Phnom Penh, 28 September, 2020

## ANNOUNCEMENT

The Ministry of Commerce has the honor to inform the public that the Ministry will organize **"The 15th Cambodian and Import-Export Goods Exhibition"** to be held from 15th to 18th December 2020 at the Koh Pich Exhibition & Convention Center, Phnom Penh, Kingdom of Cambodia.

This trade event is aiming to promote trade and investment activities, exports diversification, and commercial connectivity in contribution to economy development of Cambodia after Covid-19 crisis. Due to uncertainty of Covid-19 pandemic, the Ministry of Commerce will offer priorities to local enterprises or international companies based and having their exhibits in Cambodia to showcase their products, services, or investment projects in the event.

Meanwhile, during the event, the Ministry of Commerce in cooperation with inter-ministerial committee to combat Covid-19 will carry out necessary safety measures in accordance with national health standard.

As aforementioned, the Ministry of Commerce cordially invites traders, entrepreneurs, or investors who wish to participate in **The 15th Cambodian and Import-Export Goods Exhibition 2020** or are willing to find their investment or business partners to apply and submit their proposals to the Department of Exhibition Affairs, General Directorate of Trade Promotion of the Ministry of Commerce **no later than 15th November 2020**.

For further details, please contact the Department of Exhibition Affairs at Lot 19-61, Russian Federation Blvd, Teuk Thla Village, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Cambodia.

| | |
|---|---|
| Contact numbers: | 078 755 551 / 077 339 439<br>077 332 233 / 017 495 091 |
| E-mail Address: | ritatong19@gmail.com / neary86@gmail.com<br>vuthakep@yahoo.com / kdi_mpp@yahoo.com |

*Note: The above program is subject to be change if necessary.*

**Thank you!**